# ពិធីសារស្តីពីការបង្ក្រាប អំពើខុសច្បាប់ទៅនឹង សុវត្ថិភាពនៃទីតាំង អចិន្ត្រៃយ៍ដែលស្ថិតនៅ តំបន់ខ្ពស់រាបបាត សមុទ្រ

# ២០០៥

# ព្រះរាជក្រម

នស/រកម/១០០៥/០២៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃពិធីសារស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃទីតាំងអចិន្ត្រៃយ៍ ដែលស្ថិតនៅតំបន់ខ្ពង់រាបបាតសមុទ្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៥ នាសម័យ ប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុងកាលពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

## ស្ដីពី

## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃពិធីសារ ស្ដីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃទីតាំងអចិន្ត្រៃយ៍ ដែលស្ថិតនៅតំបន់ខ្ពង់រាបបាតសមុទ្រ

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃពិធីសារស្ដីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃទីតាំងអចិន្ត្រៃយ៍ ដែលស្ថិតនៅតំបន់ខ្ពង់រាបបាតសមុទ្រ ដែលធ្វើនៅទីក្រុងរ៉ូម នាថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៨៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

**មាត្រា ៣.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៥

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

ពរល.០៥១០.៤៥៤

នរោត្ដម សីហមុនី

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ហត្ថលេខា

ទៀ បាញ់ ញឹក ប៊ុនឆៃ

លេខៈ ៣១៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

# ពិធីសារស្តីអំពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាព នៃទីតាំងអចិន្ត្រៃយ៍ដែលស្ថិតនៅតំបន់ខ្ពង់រាបបាតសមុទ្រ

**រដ្ឋភាគីនៃពិធីសារនេះ :**

-ដោយជាភាគីនៃអនុសញ្ញាស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ

-ដោយទទួលស្គាល់ថា ហេតុផលទាំងឡាយដែលអនុសញ្ញាមានចែងលំអិតត្រូវអនុវត្តផងដែរចំពោះទីតាំងអចិន្ត្រៃយ៍ដែលស្ថិតនៅលើខ្ពង់រាបបាតសមុទ្រ។

-ដោយបានពិចារណានូវបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានោះ។

-ដោយអះអាងថា បញ្ហាទាំងឡាយដែលមិនមានចែងក្នុងពិធីសារនេះនឹងត្រូវបន្តគ្រប់គ្រងដោយ វិធាន និងគោលការណ៍ទូទៅនៃនិតិអន្តរជាតិ។

**បានព្រមព្រៀង** ដូចខាងក្រោមនេះ :

## មាត្រា១

១- បទប្បញ្ញត្តិដែលមានចែងនៅក្នុងមាត្រា ៥ មាត្រា ៧ និងមាត្រា ១០ ដល់មាត្រា ១៦ នៃអនុសញ្ញាស្តីអំពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ (បន្ទាប់ពីនេះហៅថា"អនុសញ្ញា") អនុវត្តផងដែរ ក្នុងករណីចាំបាច់ដោយអាចកែប្រែ ចំពោះបទល្មើសទាំងឡាយដូចមានចែងក្នុងមាត្រា ២ នៃពិធីសារនេះ ដែលបទល្មើសទាំងនោះត្រូវបានប្រព្រឹត្តិនៅលើឬប្រឆាំងទៅនឹងទីតាំងអចិន្ត្រៃយ៍ដែលស្ថិតនៅតំបន់ខ្ពង់រាបបាតសមុទ្រ។

២- ក្នុងករណីដែលពិធីសារនេះ មិនអនុវត្តតាមកថាខ័ណ្ឌ១ ប៉ុន្តែបទប្បញ្ញត្តិទាំងឡាយនៃពិធីសារនេះអនុវត្ត ប្រសិនបើជនល្មើស ឬជនល្មើសដោយសន្មតត្រូវបានរកឃើញលើទឹកដីរដ្ឋភាគីមួយ ក្រៅអំពីរដ្ឋដែលទីតាំងអចិន្ត្រៃយ៍ស្ថិតនៅក្នុងដែនទឹក ឬតំបន់សមុទ្រដែនដីរបស់រដ្ឋនោះ។

៣- វត្ថុបំណងនៃពិធីសារនេះ ទីតាំងអចិន្ត្រៃយ៍ (Fixed Platforms) មានន័យថា កោះសិប្បនិម្មិត សំណង់ឬអគារដែលជាប់នៅជាអចិន្ត្រៃយ៍នៅនឹងបាតសមុទ្រសំរាប់ការស្វែងរុករក ឬការធ្វើអាជីវកម្មនៃធនធានធម្មជាតិ ឬសំរាប់គោលបំណងផ្សេងទៀតខាងសេដ្ឋកិច្ច។

## មាត្រា ២

១-ជនណាម្នាក់ជាជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមួយ ប្រសិនបើជននោះប្រព្រឹត្តដោយខុសច្បាប់និងដោយចេតនា :

ក- រឹបអូស ឬធ្វើការត្រួតត្រាទៅលើទីតាំងអចិន្ត្រៃយ៍ដោយប្រើហឹង្សា ឬការគំរាមកំហែង ឬក៏ការបំភិត បំភ័យតាមទ្រង់ទ្រាយណាមួយ ឬ

ខ- ប្រព្រឹត្តនូវអំពើហឹង្សាទៅលើមនុស្សនៅលើទីតាំងអចិន្ត្រៃយ៍ ប្រសិនបើអំពើនោះអាចធ្វើអោយមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃទីតាំងអចិន្ត្រៃយ៍ ឬ

គ- បំផ្លាញទីតាំងអចិន្ត្រៃយ៍ ឬបង្កការខូចខាតដល់ទីតាំងអចិន្ត្រៃយ៍ ដែលអាចធ្វើអោយគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់វា ឬ

ឃ-ដាក់ ឬធ្វើអោយមានការដាក់ដោយមធ្យោបាយណាមួយក៏ដោយលើទីតាំងអចិន្ត្រៃយ៍នូវឧបករណ៍ឬសារធាតុដែលអាចបំផ្លិចបំផ្លាញដល់ទីតាំងអចិន្ត្រៃយ៍ ឬអាចធ្វើអោយគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់វា ឬ

ង- បង្ករបួសស្នាម ឬធ្វើឃាតជនណាម្នាក់ កាលបើអំពើនោះមានចំណងទាក់ទងជាមួយនឹងបទល្មើសមួយនៃបទល្មើសទាំងឡាយដូចមានចែងក្នុងវាក្យខ័ណ្ឌ (ក) ដល់ (ឃ) ដែលបទល្មើសនោះត្រូវបានប្រព្រឹត្តឬប៉ុនប៉ងប្រព្រឹត្ត។

២- ជនណាម្នាក់ជាជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមួយផងដែរ ប្រសិនបើជននោះ :

ក-ប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយក្នុងចំណោមបទល្មើសទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌ១ ឬ

ខ- ជំរុញជនណាម្នាក់ផ្សេងទៀតអោយប្រព្រឹត្តបទល្មើសណាមួយក្នុងចំណោមបទល្មើសទាំងនោះ ឬ ជាអ្នកសមគំនិតជាមួយនឹងជនណាម្នាក់ដែលប្រព្រឹត្តបទល្មើសបែបណាមួយនោះ ឬ

គ- គំរាមកំហែងដោយមាន ឬគ្មានលក្ខខណ្ឌដូចដែលមានចែងក្នុងច្បាប់ជាតិ ក្នុងគោលបំណងបង្ខិតបង្ខំរូបវន្តបុគ្គល ឬនីតិបុគ្គល អោយធ្វើឬមិនអោយធ្វើនូវអំពើណាមួយដូចមានចែងក្នុងកថាខ័ណ្ឌទី១ វាក្យខ័ណ្ឌ(ខ)និង (គ) ប្រសិនបើការគំរាមកំហែងនោះ អាចធ្វើអោយគ្រោះថ្នាក់ដល់សុវត្ថិភាពនៃទីតាំងអចិន្ត្រៃយ៍ ។

## មាត្រា៣

១-រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់ទាំងឡាយ ដើម្បីបង្កើតនូវសមត្ថកិច្ចរបស់ខ្លួនលើបទល្មើសនានាដូចមានចែងក្នុងមាត្រា២ នៅពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្តៈ

ក-ប្រឆាំង ឬនៅលើទីតាំងអចិន្ត្រៃយ៍ខណៈដែលវាបានស្ថិតនៅលើខ្ពង់រាបបាតសមុទ្រនៃរដ្ឋ នោះ ឬ

ខ- ដោយពលរដ្ឋណាម្នាក់នៃរដ្ឋនោះ

២- រដ្ឋភាគីអាចបង្កើតផងដែរនូវសមត្ថកិច្ចរបស់ខ្លួនលើបទល្មើសបែបណាមួយនោះនៅពេលដែលៈ

ក-បទល្មើសនោះត្រូវបានប្រព្រឹត្តដោយនិរបេតិកជន(ជនគ្មានសញ្ជាតិ) ដែលមាននិវេសនដ្ឋានជាទំលាប់របស់ខ្លួននៅក្នុងរដ្ឋនោះ ឬ

ខ- ក្នុងកំឡុងពេលនៃការប្រព្រឹត្តបទល្មើស ពលរដ្ឋណាម្នាក់នៃរដ្ឋនោះត្រូវបានឃាត់ខ្លួន ត្រូវបានគំរាមកំហែង ត្រូវបានធ្វើអោយរងរបួស ឬត្រូវបានសំលាប់ ឬ

គ- បទល្មើសនោះត្រូវបានប្រព្រឹត្តក្នុងបំណងបង្ខិតបង្ខំរដ្ឋនោះអោយធ្វើ ឬ មិនអោយធ្វើនូវអំពើណាមួយ ។

៣- រដ្ឋភាគីនិមួយៗដែលបានបង្កើតសមត្ថកិច្ចលើករណីទាំងឡាយដូចមានចែងនៅក្នុងកថាខ័ណ្ឌ ២ ត្រូវជូនដំណឹងដល់អគ្គលេខាធិការនៃអង្គការដែនសមុទ្រអន្តរជាតិ( បន្ទាប់ពីនេះហៅថា "អគ្គលេខាធិការ" ) ។ បន្ទាប់មកទៀត ប្រសិនបើរដ្ឋភាគីនោះលុបចោលនូវសមត្ថកិច្ចនោះ រដ្ឋភាគីនោះត្រូវជូនដំណឹងដល់អគ្គលេខាធិការ ។

៤- រដ្ឋភាគីនិមួយៗត្រូវចាត់វិធានការចាំបាច់នានា ដើម្បីបង្កើតសមត្ថកិច្ចរបស់ខ្លួនលើបទល្មើសនានាដូចមានចែងក្នុងមាត្រា២ ក្នុងករណីដែលជនល្មើសដោយសន្មតមានវត្តមាននៅក្នុងទឹកដីរបស់ខ្លួន ហើយរដ្ឋនោះមិនធ្វើបត្យាប័នជនល្មើសនោះទៅអោយរដ្ឋភាគីណាមួយក្នុងចំណោមរដ្ឋភាគីទាំងអស់ដែលបានបង្កើតសមត្ថកិច្ចរបស់ខ្លួន ដោយអនុលោមតាមកថាខ័ណ្ឌ១ និង២ នៃមាត្រានេះ ។

៥- ពិធីសារនេះ រាប់បញ្ចូលទាំងសមត្ថកិច្ចព្រហ្មទណ្ឌដែលត្រូវបានអនុវត្តស្របទៅតាមច្បាប់ជាតិ ។

## មាត្រា៤

គ្មានបទបញ្ញត្តិណាមួយនៃពិធីសារនេះ ប៉ះពាល់តាមរបៀបណាមួយទៅលើវិធាននៃនិតិអន្តរជាតិដែលទាក់ទងទៅនឹងទីតាំងអចិន្ត្រៃយ៍ដែលស្ថិតនៅតំបន់ខ្ពង់រាបបាតសមុទ្រនោះឡើយ ។

## មាត្រា៥

១- ពិធីសារនេះ ត្រូវបានបើកចំហសំរាប់ការចុះហត្ថលេខា នៅទីក្រុងរ៉ូម នាថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៨៨ និងនៅទីស្នាក់ការនៃអង្គការដែនសមុទ្រអន្តរជាតិ ( បន្ទាប់ពីនេះហៅថា "អង្គការ" ) ចាប់ពីថ្ងៃទី១៤ ខែ មិនា ឆ្នាំ១៩៨៨ ដល់ថ្ងៃទី០៩ ខែមិនា ឆ្នាំ១៩៨៩ សំរាប់រដ្ឋណាមួយដែលបានចុះហត្ថលេខាលើអនុសញ្ញា ។ បន្ទាប់មក ពិធីសារនេះនៅតែចំហសំរាប់ការសុំចូលជាសមាជិក ។

២-រដ្ឋនានា អាចបញ្ជាក់ពីការយល់ព្រមរបស់ខ្លួន ក្នុងការគោរពតាមពិធីសារនេះបាន ដោយៈ

ក- ការចុះហត្ថលេខាដោយគ្មានលក្ខខ័ណ្ឌផ្តល់សច្ចាប័ន ការព្រមទទួលយក ឬ ការយល់ព្រម ឬ

ខ- ការចុះហត្ថលេខាដោយឋិតក្រោមលក្ខខណ្ឌសច្ចាប័ន ការព្រមទទួលយក ឬ ការយល់ព្រម ដែលតំរូវផ្តល់សច្ចាប័ន ការព្រមទទួលយក ឬការយល់ព្រមឬ

គ- ការចូលជាសមាជិក

៣- ការផ្តល់សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬ ការចូលជាសមាជិក មានប្រសិទ្ធិភាព ដោយការដាក់ជូននូវលិខិតុបករណ៍មួយទៅអគ្គលេខាធិការ ។

៤- មានតែរដ្ឋណាមួយដែលបានចុះហត្ថលេខាលើអនុសញ្ញា ដោយគ្មានលក្ខខ័ណ្ឌផ្តល់សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬ ដែលបានផ្តល់សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬ បានចូលជាសមាជិកនៃអនុសញ្ញារួចហើយ ទើបអាចក្លាយជាភាគីនៃពិធីសារនេះ។

## មាត្រា៦

១- ពិធីសារនេះ ចូលជាធរមាននៅ៩០ថ្ងៃ បន្ទាប់ពីរដ្ឋចំនួន ០៣ បានចុះហត្ថលេខាលើពិធីសារនេះ ដោយគ្មានលក្ខខ័ណ្ឌផ្តល់សច្ចាប័ន ការព្រមទទួលយក ឬ ការយល់ព្រម ឬ បានដាក់លិខិតុបករណ៍សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬ ការចូលជាសមាជិក។ ទោះជាយ៉ាងណាក្តី ក៏ពិធីសារនេះ មិនអាចចូលជាធរមានបានទេ មុនពេលដែលអនុសញ្ញាចូលជាធរមានរួច។

២- ចំពោះរដ្ឋមួយដែលដាក់លិខិតុបករណ៍សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬ ការចូលជាសមាជិកនៃពិធីសារនេះ បន្ទាប់ពីលក្ខខ័ណ្ឌនានាសំរាប់ការចូលជាធរមានត្រូវបានបំពេញរួចហើយនោះ សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬ ការសុំចូលជាសមាជិកនេះ ចាប់មានសុពលភាព បន្ទាប់ពី៩០ថ្ងៃ បន្ទាប់ពីថ្ងៃនៃការដាក់លិខិតុបករណ៍បែបនោះមួយ ។

## មាត្រា៧

១- ពិធីសារនេះ អាចត្រូវបានប្រកាសមិនយល់ព្រមដោយរដ្ឋភាគីណាមួយ នៅពេលណាក៏បាន បន្ទាប់ពីផុតកំណត់រយៈពេល១ឆ្នាំ ចាប់ពីថ្ងៃដែលពិធីសារនេះ ចូលជាធរមានសំរាប់រដ្ឋនោះ។

២- ការប្រកាសមិនយល់ព្រម អាចមានសុពលភាពបាន ដោយការដាក់លិខិតុបករណ៍នៃការប្រកាសមិនយល់ព្រមនោះ ជូនទៅអគ្គលេខាធិការ។

៣- សេចក្តីប្រកាសមិនយល់ព្រម ចាប់មានសុពលភាពរយៈពេលមួយឆ្នាំ ឬ យូរជាងនេះ ដូចដែលបានបញ្ជាក់នៅក្នុងលិខិតុបករណ៍នៃសេចក្តីប្រកាសមិនយល់ព្រម បន្ទាប់ពីបានទទួលយកលិខិតុបករណ៍ នៃសេចក្តីប្រកាសមិនយល់ព្រមនេះ ដោយអគ្គលេខាធិការ។

៤- សេចក្តីប្រកាសមិនយល់ព្រមនៃអនុសញ្ញា ដែលធ្វើឡើងដោយរដ្ឋភាគីណាមួយ ត្រូវបានចាត់ទុកថាជាសេចក្តីប្រកាសមិនយល់ព្រមនៃពិធីសារនេះ ដោយភាគីនោះ។

## មាត្រា៨

១- សន្និសីទមួយអាចត្រូវបានកោះប្រជុំដោយ "អង្គការ" សំរាប់គោលបំណងកែប្រែ ឬ វិសោធនកម្មលើពិធីសារនេះ ។

២- អគ្គលេខាធិការ អាចកោះប្រជុំរដ្ឋភាគីទាំងឡាយនៃពិធីសារនេះ ដើម្បីធ្វើសន្និសិទពិនិត្យឡើងវិញ ឬ វិសោធនកម្មពិធីសារនេះ ទៅតាមសំណើចំនួន១ភាគ៣នៃរដ្ឋភាគី ឬ រដ្ឋភាគីចំនួន ៥ ប្រសិនបើតួលេខខាងក្រោយនេះខ្ពស់ជាង។

៣- លិខិតុបករណ៍ណាមួយនៃការផ្តល់សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬ ការចូលជាសមាជិក ដែលត្រូវបានដាក់ជូន បន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃវិសោធនកម្មលើពិធីសារនេះ ត្រូវបានចាត់ទុកថា អនុវត្តតាមពិធីសារដែលបានធ្វើវិសោធនកម្មរួច។

## មាត្រា ៩

១- ពិធីសារនេះ ត្រូវបានដាក់តម្កល់ទុកនៅអគ្គលេខាធិការ។

២- អគ្គលេខាធិការត្រូវ៖

ក- ផ្តល់ពត៌មានដល់រដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើពិធីសារនេះ ឬ បានចូលជាសមាជិកនៃពិធីសារនេះ ព្រមទាំងសមាជិកទាំងអស់នៃអង្គការនេះអោយបានដឹងអំពី៖

(១)- ហត្ថលេខាថ្មីនីមួយៗ ឬ ការដាក់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬការចូលជាសមាជិក ព្រមជាមួយនឹងកាលបរិច្ឆេទ។

(២)- កាលបរិច្ឆេទចូលជាធរមាននៃពិធីសារនេះ

(៣)- ការដាក់តម្កល់លិខិតុបករណ៍ណាមួយនៃសេចក្តីប្រកាសមិនយល់ព្រមលើពិធីសារនេះ រួមទាំងកាលបរិច្ឆេទដែលបានទទួល និង កាលបរិច្ឆេទដែលសេចក្តីប្រកាសមិនយល់ព្រមចាប់មានសុពលភាព។

(៤)- ការទទួលនូវសេចក្តីប្រកាស ឬ សេចក្តីជូនដំណឹងណាមួយ ដែលបានធ្វើឡើងស្របតាមពិធីសារ ឬអនុសញ្ញា ដែលជាប់ទាក់ទងទៅនឹងពិធីសារនេះ។

ខ-បញ្ជូនឯកសារចំលងពិតដែលបានបញ្ជាក់ជាផ្លូវការនៃពិធីសារនេះទៅអោយរដ្ឋទាំងអស់ដែលបានចុះហត្ថលេខា ឬ បានចូលជាសមាជិកនៃពិធីសារនេះ។

៣- នៅពេលដែលពិធីសារនេះចូលជាធរមាន ឯកសារចំលងពិតដែលបានបញ្ជាក់ជាផ្លូវការនោះ ត្រូវបានបញ្ជូនដោយអ្នកថែរក្សាឯកសារទៅជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ សំរាប់ការចុះបញ្ជី និង ផ្សព្វផ្សាយ ដោយអនុលោមទៅតាមមាត្រា១០២នៃធម្មនុញ្ញសហប្រជាជាតិ។

## មាត្រា១០

ពិធីសារនេះ ត្រូវបានរៀបរៀងឡើងជាច្បាប់ដើមតែមួយ ជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និង អេស្ប៉ាញ អត្ថបទនិមួយៗមានតំលៃស្មើគ្នា។

**ដើម្បីជាសាក្សី** អ្នកដែលចុះហត្ថលេខាខាងក្រោម ដោយបានផ្តល់សិទ្ធិអោយដ៏ត្រឹមត្រូវដោយរដ្ឋាភិបាលរៀងៗខ្លួនសំរាប់វត្ថុបំណងនោះ បានចុះហត្ថលេខាលើអនុសញ្ញានេះ។

ធ្វើនៅទីក្រុងរ៉ូម ថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៨៨